សួស្តី នៅក្នុងរូបភាពនេះ គឺនិយាយអំពីការធ្វើដំណើរតាមយន្តហោះ។
ដែលនៅក្នុងរូបភាពទី ១ យើងឃើញមានបុរសម្នាក់ គាត់ពាក់អាវសដៃខ្លី
ជាមួយនឹងខោខ្លីពណ៌សដែរ។ គាត់គឺជាអ្នកទេសចរ ដោយសារតែគាត់មានថ្ងៃឈប់សម្រាក
ដូច្នេះគាត់ក៏បានធ្វើដំណើរមកលំហែកាយនៅឆ្នេរសមុទ្រ ដោយយើងឃើញថ្ងៃនេះ
មានអាកាសធាតុល្អ យើងឃើញមានពន្លឺថ្ងៃក្តៅល្មម និងមានដុំពពកជាច្រើន
ដូច្នេះគាត់ក៏បានមកអង្គុយសម្រាកលំហែកាយផ្អែកនឹងកៅអីនៅជិតមាត់សមុទ្រ
និងមានពាក់វ៉ែនតាការពារកម្តៅថ្ងៃ ដើម្បីកុំឲ្យពន្លឺថ្ងៃចាំងត្រូវភ្នែករបស់គាត់។
អញ្ចឹងគាត់អង្គុយមើលទេសភាពបណ្តើរ គាត់បឺតទឹកដូងបណ្តើរ ដោយប្រើទុយោ ដោយប្រើទុយោ
អញ្ចឹងយើងដឹងហើយថាដូង គឺយើងអាចញ៉ាំទឹករបស់វាក៏បាន
និងក្រោយពេលដែលយើងញ៉ាំទឹកអស់ យើងអាចយកដូងនោះទៅកាប់ ឬក៏ទៅពុះ
ដើម្បីយកសាច់របស់វានៅខាងក្នុងមកញ៉ាំ។ និងសាច់របស់វា
ក៏អាចយកទៅធ្វើជាដូងក្រឡុកក៏បានដែរ និងនៅខាងក្រោយបុរសម្នាក់នោះ
យើងឃើញមានដើមដូង យើងឃើញមានដើមដូង និងផ្លែដូង។
ជាធម្មតានៅតំបន់ឆ្នេរសមុទ្រគឺមានដើមដូង និងផ្លែដូងច្រើន ដូច្នេះនៅពេលដែលភ្ញៀវទេសចរ
គាត់មកសម្រាកលំហែកាយនៅឆ្នេរសមុទ្រ ភាគច្រើនគឺគាត់ចូលចិត្តញ៉ាំដូង ដោយសារតែដូង
ទឹករបស់វា គឺត្រជាក់និងផ្អែមឆ្ងាញ់។

បន្ទាប់មកទៀត រូបភាពទី ទី ២ រូបភាពទី ២ ថ្ងៃឈប់សម្រាករបស់គាត់ត្រូវ
ថ្ងៃឈប់សម្រាករបស់គាត់ត្រូវបានបញ្ចប់ ត្រូវបានបញ្ចប់
ដូច្នេះគាត់ត្រូវត្រលប់ទៅប្រទេសរបស់គាត់វិញ ដើម្បីធ្វើការធម្មតា។
អញ្ចឹងយើងឃើញគាត់បានហៅតាក់ស៊ី ដើម្បីឲ្យតាក់ស៊ីមកយកគាត់ទៅព្រលានយន្តហោះ
ដើម្បីជិះយន្តហោះត្រលប់ទៅប្រទេសរបស់គាត់វិញ។ យើងឃើញឡានតាក់ស៊ី
គឺមានសញ្ញាសម្គាល់នៅខាងលើ នៅខាងលើឡានគឺមានផ្លាកដាក់ គឺមានផ្លាកប្រាប់ ប្រាប់ថា
នេះគឺជាឡានតាក់ស៊ី គឺមានផ្លាកដែលសរសេរអក្សរតាក់ស៊ី អញ្ចឹងងាយស្រួលសម្រាប់ភ្ញៀវ គាត់
គាត់ហៅ អញ្ចឹងងាយស្រួលសម្រាប់ភ្ញៀវ គាត់ហៅ និងយើងឃើញអ្នកបើកឡានតាក់ស៊ី
គឺអង្គុយនៅខាងមុខ។ គាត់បើកយ៉ាងយកចិត្តទុកដាក់ និងភ្ញៀវគឺអង្គុយនៅខាងក្រោយ
អញ្ចឹងបុរសម្នាក់នោះគឺគាត់អង្គុយនៅខាងក្រោយ
ដើម្បីឲ្យអ្នកបើកឡានតាក់ស៊ីយកគាត់ទៅព្រលានយន្តហោះ
ដើម្បីជិះយន្តហោះទៅប្រទេសរបស់គាត់វិញ។ អញ្ចឹងបើទោះបីជាគាត់អង្គុយនៅក្នុងឡាន
គាត់នៅតែពាក់វ៉ែនតាការពារកម្តៅថ្ងៃ ពីព្រោះងាយស្រួលនៅពេលដែលគាត់ចេញ
នៅពេលដែលគាត់ចុះពីក្នុងឡាន ចេញទៅខាងក្រៅ បើនៅខាងក្រៅមានពន្លឺថ្ងៃ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងពន្លឺថ្ងៃមិនចាំងត្រូវភ្នែករបស់គាត់ទេ។ ដោយសារតែគាត់ពាក់វ៉ែនតាការពារកម្ដៅថ្ងៃ។
អញ្ចឹងយើងឃើញអ្នកបើកឡានតាក់ស៊ីកំពុងតែបើកនៅតាមផ្លូវដើម្បីយក
ដើម្បីយកបុរសម្នាក់នោះទៅព្រលានយន្តហោះ ដើម្បីយកបុរសម្នាក់នោះទៅព្រលានយន្តហោះ។

បន្ទាប់មកទៀតរូបភាពទី ៣ រូបភាពទី ៣ ឡានតាក់ស៊ីក៏បានបើកមកដល់ព្រលានយន្តហោះ
ដែលយើងឃើញនៅព្រលានយន្តហោះយើងឃើញមានផ្លាកសញ្ញាជាច្រើនដើម្បីប្រាប់ភ្ញៀវ
ដើម្បីប្រាប់ភ្ញៀវ ផ្លូវណាត្រូវទៅកន្លែងណា ផ្លូវណាត្រូវទៅកន្លែងណា។
ដោយយើងឃើញនៅក្នុងរូបភាពទី ៣ យើងឃើញមានផ្លាកសញ្ញាពីរ។ ផ្លាកសញ្ញានៅលើទ្វារទី ១
គឺឃើញយន្តហោះចុះចតខាងក្រោម អញ្ចឹងមានន័យថាផ្លូវនោះគឺសម្រាប់ភ្ញៀវ សម្រាប់ភ្ញៀវគាត់ចុះ
គាត់ចុះពីលើយន្តហោះ គាត់អាចចេញតាមច្រកទ្វារនោះ។ អញ្ចឹង និងយើងឃើញសញ្ញាមួយទៀត
គឺយន្តហោះឡើង គឺយន្តហោះឡើងមានន័យថាភ្ញៀវដែលគាត់ត្រូវការ
ភ្ញៀវដែលគាត់ធ្វើដំណើរត្រលប់ទៅប្រទេសរបស់គាត់វិញ គាត់ត្រូវ
គាត់ត្រូវធ្វើដំណើរទៅតាមផ្លាកសញ្ញានោះ គាត់ត្រូវធ្វើដំណើរទៅតាមផ្លាកសញ្ញានោះ។
អញ្ចឹងអ្នកបើកឡានតាក់ស៊ីបានបើកទៅ បានបើកទៅតាមផ្លាកសញ្ញាដែលយន្តហោះឡើង
ដែលយន្តហោះឡើងនោះ ដើម្បីដាក់ភ្ញៀវរបស់គាត់ ដើម្បីដាក់ភ្ញៀវរបស់គាត់ចុះ
អញ្ចឹងដើម្បីដាក់ភ្ញៀវរបស់គាត់ចុះ។

បន្ទាប់មកទៀតរូបភាពទី ៤ រូបភាពទី ៤ ក្រោយពេលដែលបុរសម្នាក់នោះ
គាត់បានមកដល់ព្រលានយន្តហោះ គាត់ក៏បានឲ្យលុយតាក់ស៊ី អញ្ចឹងតាក់ស៊ីគឺគិតជាគីឡូម៉ែត្រ
អញ្ចឹងទៅតាម ទៅតាមតាក់ស៊ីខ្លះ គឺគាត់គិតមួយគីឡូម៉ែត្រគឺតម្លៃ ៤០០០ រៀល ឬក៏ ១ ដុល្លារ។
អញ្ចឹងទៅតាមតម្លៃដែលគាត់ដាក់ ប៉ុន្តែជាទូទៅគឺយើងគិតទៅតាមគីឡូម៉ែត្រ
អញ្ចឹងគឺគិតទៅតាមគីឡូម៉ែត្រ។ អញ្ចឹងក្រោយពេលដែលគាត់ឲ្យលុយទៅតាក់ស៊ីរួចរាល់ហើយ
គាត់ក៏បានដើរចូលមកខាងក្នុងទៅតាមផ្លាកសញ្ញា ដែលបានបង្ហាញប្រាប់នៅខាងក្រៅ។
អញ្ចឹងយើងឃើញរូបភាពទី ៤ គាត់ដើរចូលមកខាងក្នុង ប៉ុន្តែមុនពេលដែលគាត់ឡើងយន្តហោះ
គាត់ត្រូវ គាត់ត្រូវត្រួតពិនិត្យ គាត់ត្រូវត្រួតពិនិត្យ និងគាត់ត្រូវឆ្លងកាត់កន្លែងជាច្រើនជាមុនសិន។
អញ្ចឹងកន្លែងទី ១ គាត់ត្រូវមកត្រួតពិនិត្យវ៉ាលិសរបស់គាត់ ដើម្បីថតអ៊ិច-រ៉េ
ដើម្បីឲ្យច្បាស់ថាវ៉ាលិសរបស់គាត់ មិនមាន មិនមានរបស់ហាមឃាត់។
អញ្ចឹងយើងឃើញក្រោយពេលដែលគាត់ដើរមកដល់កន្លែងត្រួតពិនិត្យនោះ
គាត់បានលើកវ៉ាលិសរបស់គាត់ដាក់នៅលើម៉ាស៊ីន ម៉ាស៊ីនក៏បានរុញចូលទៅ[ក្នុង] ចូលទៅខាងក្នុង
ដើម្បីឲ្យបុគ្គលិកនៅទីនោះគាត់ធ្វើការត្រួតពិនិត្យ។ អញ្ចឹងយើងឃើញដៃរបស់គាត់ម្ខាងកាន់វ៉ាលិស
ដើម្បីឲ្យវ៉ាលិស កាន់វ៉ាលិសដើម្បី ដើម្បីរុញវ៉ាលិសនោះ ឬក៏ម៉ាស៊ីននោះ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គឺបានរុញវ៉ាលិសនោះចូលទៅក្នុង ចូលទៅខាងក្នុងដើម្បីធ្វើការត្រួតពិនិត្យ។
អញ្ចឹងបុគ្គលិកនៅក្នុងព្រលានយន្តហោះ ដែលជាអ្នកឆែកមើលអ៊ិច-រ៉េ គាត់បានអង្គុយ
គាត់បានអង្គុយមើលកុំព្យូទ័ររបស់គាត់ ឬក៏មើលម៉ាស៊ីនសម្រាប់ឆែក មើលម៉ាស៊ីនរបស់ សម្រាប់ឆែក
ដើម្បីឲ្យដឹងថានៅខាងក្នុងគឺមិនមានរបស់ដែលហាមឃាត់នោះទេ ដើម្បីនៅខាងក្នុង
នៅខាងក្នុងគ្មានរបស់] មាន ដើម្បីឲ្យច្បាស់ថារបស់នៅខាងក្នុងអត់មានរបស់ដែល
ដែលហាមឃាត់។ អញ្ចឹងយើងឃើញបុគ្គលិកដែលធ្វើការនៅទីនោះ គឺត្រូវមានការប្រុងប្រយ័ត្ន
ពីព្រោះប្រសិនបើអត់មានការប្រុងប្រយ័ត្នទេ
ពេលខ្លះក៏អាចមានបញ្ហាកើតឡើងនៅក្នុងប្រទេសរបស់គាត់ នៅក្នុងប្រទេសរបស់គាត់
អញ្ចឹងអាចមានបញ្ហាកើតឡើងនៅក្នុងប្រទេសរបស់គាត់បាន។ ដូច្នេះគាត់ត្រូវធ្វើការ
គាត់ត្រូវធ្វើការយ៉ាងប្រុងប្រយ័ត្ន។ អញ្ចឹងយើងឃើញគាត់អង្គុយ
ដែលពាក់ឯកសណ្ឋានជាអ្នកត្រួតពិនិត្យអ៊ិច-រ៉េ ដែលពាក់ឯកសណ្ឋានជាអ្នកត្រួតពិនិត្យអ៊ិច-រ៉េ
ដែលមានមួក និងឯកសណ្ឋាន ដែលមានមួក និងឯកសណ្ឋានពណ៌ស
និងនៅខាងមុខគាត់យើងឃើញមានម៉ាស៊ីនសម្រាប់មើល សម្រាប់មើល
ឆែកមើលនៅខាងក្នុងវ៉ាលិសរបស់ភ្ញៀវ។ អញ្ចឹងយើងឃើញគាត់
គាត់ឆែកមើលយ៉ាងយកចិត្តទុកដាក់។

រូបភាពទី ៥ ក្រោយពេលដែលគាត់ធ្វើអ៊ិច-រ៉េទៅលើវ៉ាលិសរបស់គាត់រួចរាល់ហើយ
គាត់ក៏បានមកកន្លែងមួយទៀត។ ដោយសារតែមានភ្ញៀវជាច្រើន ដោយសារតែមានភ្ញៀវជាច្រើន
គាត់ គាត់ គាត់ឈររង់ចាំ ដូច្នេះគាត់ត្រូវឈរតម្រង់ជួរនៅខាងក្រោយគេ
គាត់ត្រូវឈរតម្រង់ជួរនៅខាងក្រោយគេ។ អញ្ចឹងនៅពេលដែលគាត់កំពុងតែឈរតម្រង់ជួរនោះ
យើងឃើញគាត់ស្ដាប់ យើងឃើញគាត់មានដាក់កាសនៅត្រចៀករបស់គាត់។
អញ្ចឹងគាត់ស្ដាប់ភ្លេងបណ្ដើរ គាត់ឈរតម្រង់ជួរ ដើម្បីចូលទៅកន្លែងមួយទៀត
ដើម្បីចូលទៅកន្លែងមួយទៀត ដើម្បីធ្វើការឆែកនូវទម្ងន់ ដើម្បីធ្វើការឆែកនូវទម្ងន់វ៉ាលិសរបស់គាត់
ធ្វើការឆែកនូវទម្ងន់វ៉ាលិសរបស់គាត់ និងធ្វើការទិញសំបុត្រ និងធ្វើការទិញសំបុត្រផ្សេងៗទៀត។
អញ្ចឹងនៅព្រលានយន្តហោះ គឺធ្វើ មុនពេលដែលយើងឡើងជិះយន្តហោះ យើងត្រូវ យើងត្រូវចូល
យើងត្រូវត្រួតពិនិត្យមួយដំណាក់កាលទៅមួយដំណាក់កាល និង
ពីមួយដំណាក់កាលទៅមួយដំណាក់កាល អញ្ចឹងដោយសារតែយើងឃើញមាន
យើងឃើញមានមនុស្សជាច្រើននៅព្រលានយន្តហោះ ដូច្នេះម្នាក់ៗ គាត់ត្រូវឈរតម្រង់ជួរ
ដោយយើងឃើញ ដោយយើងឃើញគាត់គឺឈរនៅខាងក្រោយ ដៃរបស់គាត់ខាងស្ដាំគឺកាន់វ៉ាលិស
កាន់វ៉ាលិសរបស់គាត់ និងបុរសដែលគាត់នៅឈរខាងមុខ
យើងឃើញគាត់មានកាន់វ៉ាលិសរបស់គាត់ដែរ គឺគាត់ដាក់នៅជិតខ្លួនរបស់គាត់ និងស្ត្រីម្នាក់ទៀត

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

យើងឃើញគាត់ឈររង់ចាំដែរ គាត់មានកាន់វ៉ាលិសរបស់គាត់នៅខាងមុខដែរ និងបុរសម្នាក់ទៀត គឺគាត់អត់មានវ៉ាលិសខោអាវទេ គឺគាត់កាន់តែវ៉ាលិសតូចមួយ គឺវ៉ាលិសដាក់ឯកសារធ្វើការ ឬក៏ដាក់កុំព្យូទ័រ។ អញ្ចឹងពួកគាត់ទាំងអស់គ្នាកំពុងតែឈររង់ចាំ ដើម្បីចូល ដើម្បីចូលត្រួតពិនិត្យកន្លែងមួយទៀត។

បន្ទាប់មកទៀតរូបភាពទី ៦ រូបភាពទី ៦ ក្រោយពេលដែល ក្រោយពេលដែល ក្រោយពេលមនុស្សទាំងអស់គាត់ឆែករួចរាល់ហើយ អញ្ចឹងដល់វេនគាត់ត្រូវចូលម្តង។ អញ្ចឹងយើងឃើញគាត់បានលើកវ៉ាលិសរបស់គាត់ ដើម្បីដាក់ទៅលើជញ្ជីង ដើម្បីថ្លឹងមើលទម្ងន់វ៉ាលិសរបស់គាត់។ ពីព្រោះនៅក្នុងព្រលាន នៅក្នុងយន្តហោះ ពេលខ្លះគឺមានការកំណត់នូវទម្ងន់ គឺមានការកំណត់នូវទម្ងន់ ប្រសិនបើទម្ងន់វ៉ាលិសរបស់យើងលើស យើងត្រូវបង់លុយបន្ថែម អញ្ចឹងប្រសិនបើវ៉ាលិសរបស់យើងលើស យើងត្រូវបង់លុយបន្ថែមទៅតាមទម្ងន់ដែលលើសនោះ។ អញ្ចឹងទៅតាមទម្ងន់ដែលលើស ដែលលើសនោះ អញ្ចឹងកន្លែងខ្លះគឺគាត់កំណត់ទម្ងន់តែ ៣០ គីឡូ ឬក៏អីវ៉ាន់ដែលយកតាមខ្លួនកំណត់តែ ៧ គីឡូ អញ្ចឹងទៅតាម ទៅតាម ទៅតាមជើងយន្តហោះដែលគាត់ហោះហើរ។ អញ្ចឹងយើងឃើញបុគ្គលិកដែលគាត់ជាអ្នកឆែកមើលទម្ងន់វ៉ាលិស និង និងគាត់គឺជាអ្នកជូនសំបុត្រយន្តហោះ ជូនយន្តហោះ សំបុត្រយន្តហោះឲ្យភ្ញៀវ នៅពេលដែលភ្ញៀវធ្វើការកុម្ម៉ង់ នៅពេលដែលភ្ញៀវធ្វើការកុម្ម៉ង់កៅអី។ អញ្ចឹងយើងឃើញគាត់មានពាក់ឯកសណ្ឋានជាអ្នកត្រួត គាត់មានពាក់ឯកសណ្ឋានជាអ្នកត្រួត គាត់បានពាក់ឯកសណ្ឋានជាបុគ្គលិកធ្វើការនៅព្រលានយន្តហោះ ដែលមានកុំព្យូទ័រមួយនៅខាងមុខគាត់ មានកុំព្យូទ័រមួយនៅខាងមុខគាត់ ដែលគាត់មានពាក់ យើងឃើញគាត់ពាក់ឯកសណ្ឋាន និងពាក់ក្រវាត់កផងដែរ។ អញ្ចឹងយើងឃើញក្រោយពេលដែលបុរសម្នាក់នោះ គាត់បានដើរចូលមក គាត់បានដើរចូលមកកន្លែងពិនិត្យមើលទម្ងន់វ៉ាលិសរបស់គាត់។ អញ្ចឹងគាត់បានលើកវ៉ាលិសរបស់គាត់ដាក់ឡើងទៅលើ ដើម្បីធ្វើការថ្លឹងវ៉ាលិសរបស់គាត់។ អញ្ចឹងក្រោយពេលដែលបុគ្គលិកគាត់ធ្វើការថ្លឹងទម្ងន់វ៉ាលិស ធ្វើការថ្លឹងទម្ងន់វ៉ាលិសរួចរាល់ហើយ។ អញ្ចឹងគាត់អាចចេញជាក្រដាស ឬក៏ឯកសារមួយសន្លឹកទៀត ដែល ដែលអាចឲ្យបុរសម្នាក់នោះ គាត់អាច គាត់អាចបង្ហាញនៅពេលដែលគាត់ នៅពេលដែលគាត់ នៅពេលដែលគាត់ នៅពេលដែលគាត់ដើរចូលទៅក្នុងយន្តហោះ។ អញ្ចឹងមានន័យថាក្រដាស ក្រដាសនោះ ក្រដាសនោះគឺ គឺ គឺប្រើសម្រាប់នៅពេលដែលគាត់ឡើងទៅលើយន្តហោះ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គាត់ត្រូវបង្ហាញក្រដាសនោះទៅបុគ្គលិកនៅកន្លែងនោះជាមុនសិន។
ប្រសិនបើគាត់អត់មានក្រដាសនោះទេ គាត់អត់អាចឡើងទៅលើយន្តហោះបានទេ។

និងរូបភាពទី ៧ រូបភាពទី ៧ ក្រោយពេលដែលគាត់
ក្រោយពេលដែលគាត់ថ្លឹងទម្ងន់វ៉ាលិសរបស់គាត់រួចរាល់ហើយ ថ្លឹងវ៉ាលិស
ទម្ងន់វ៉ាលិសរបស់គាត់រួចរាល់ហើយ។ គាត់ក៏បាន គាត់ក៏បានប្រាប់ទៅបុគ្គលិកដើម្បី ដើម្បីប្រាប់អំពី
ប្រាប់កៅអីដែលគាត់ចង់អង្គុយ។ អញ្ចឹងកៅអីយើងមានកៅអីជិតបង្អួច យើងមាន
យើងមានកៅអីជាប់បង្អួច។ អញ្ចឹងអ្នកខ្លះគឺគាត់អង្គុយ អ្នកខ្លះគឺគាត់ចូលចិត្តអង្គុយកៅអីជាប់បង្អួច
ពីព្រោះគាត់អាចមើលទេសភាពនៅខាងក្រៅ។ អញ្ចឹងបុរសម្នាក់នោះគាត់ បុរសម្នាក់នោះ
គាត់ចង់អង្គុយកៅអីជាប់បង្អួច។ អញ្ចឹងគាត់ក៏បានប្រាប់បុគ្គលិក គាត់ក៏បានប្រាប់បុគ្គលិកដែល
ដែលជាអ្នកត្រួតពិនិត្យមើល ដែលជាអ្នកត្រួតពិនិត្យមើលសំបុត្រយន្តហោះ និងអ្នកដែលចេញ
អ្នកដែលចេញសំបុត្រយន្តហោះឲ្យទៅភ្ញៀវ និងអ្នកដែលថ្លឹង និងអ្នកដែលថ្លឹងទម្ងន់វ៉ាលិសនោះ។
អញ្ចឹងគាត់បានប្រាប់ទៅបុរសម្នាក់នោះ តើគាត់ចង់អង្គុយកៅអីនៅជាប់នឹងបង្អួច។
អញ្ចឹងយើងដឹងហើយថានៅក្នុងយន្តហោះគឺមានផ្លូវតូចមួយប្រើសម្រាប់
មានផ្លូវតូចមួយសម្រាប់ឲ្យភ្ញៀវគាត់ដើរ អញ្ចឹងមានកៅអីសងខាង ម្ខាងមានកៅអីបី
ម្ខាងទៀតមានកៅអីបី អញ្ចឹងទៅតាមយន្តហោះ។ យន្តហោះខ្លះមួយចំហៀងគឺមានកៅអីបី
[អញ្ចឹង]យន្តហោះខ្លះគាត់អាចមានកៅអីច្រើន។ អញ្ចឹងមានផ្លូវដើរនៅកណ្ដាលមួយប្រើ
មានផ្លូវដើរនៅកណ្ដាលមួយ ដើម្បីឲ្យភ្ញៀវ នៅពេលដែលគាត់ដើរចូល
គាត់អាចដើរចូលទៅរកកន្លែងអង្គុយ និងពេលខ្លះគាត់ដើរចូលទៅបន្ទប់ទឹក អញ្ចឹងងាយស្រួល
អញ្ចឹងងាយស្រួលនៅខាងក្នុងនោះ ងាយស្រួលនៅខាងក្នុងនោះ។

និងបន្ទាប់មកទៀតរូបភាពទី ៨ ក្រោយពេលដែលគាត់ ក្រោយពេលដែលគាត់ប្រើ
ក្រោយពេលដែលគាត់ជ្រើសរើសកៅអីអង្គុយរួចរាល់ហើយ អញ្ចឹងគាត់ក៏បាន
គាត់ក៏បានក្រដាសមួយទៀត ដែលយើងហៅថា boarding pass។ boarding pass
គឺជាក្រដាសមួយដែលគាត់ គឺជាក្រដាសមួយដែលសរសេរអំពីលេខកៅអី សរសេរអំពី
សរសេរអំពីលេខកៅអី និងសរសេរអំពីឈ្មោះយន្តហោះដែលត្រូវហោះហើរ
និងសរសេរអំពីច្រកទ្វារដែលគាត់ត្រូវដើរចូល។ អញ្ចឹងក្រដាសនោះគឺមាន[សារ]
ក្រដាសនោះគឺសំខាន់ និងភ្ជាប់ ក្រដាសនោះគឺសំខាន់ និងពេលខ្លះគឺយើងត្រូវភ្ជាប់ជាមួយនឹងសំបុត្រ
ជាមួយនឹងសំបុត្រយន្តហោះ អញ្ចឹងក្រដាស ប្រសិនបើអត់មានក្រដាសនោះ
យើងអត់អាចឡើងទៅលើយន្តហោះបានទេ ពីព្រោះដោយសារតែយើងអត់ដឹងថា
តើយើងត្រូវអង្គុយកៅអីណា យើងត្រូវឡើងយន្តហោះមួយណា។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងនៅពេលដែលយើងរៀបឡើងទៅលើយន្តហោះ យើងមានច្រកមួយទៀត និងមាន យើងមានច្រកផ្លូវមួយទៀត និងមានបុគ្គលិកនៅទីនោះ គាត់ធ្វើការឆែកម្ដងទៀត។ អញ្ចឹងនៅពេលដែលយើងដើរចូលទៅទីនោះ យើងអាចហុចក្រដាសនោះទៅឲ្យបុគ្គលិក ដែលគាត់ធ្វើការនៅទីនោះ បុគ្គលិកធ្វើការនៅទីនោះ គាត់នឹងហែកយក យកមួយផ្នែកដើម្បីទុក និងមួយផ្នែកទៀតគាត់[បាន] និងមួយផ្នែកទៀតគាត់ហុចឲ្យយើងវិញ ដើម្បីឲ្យយើង ដើម្បីឲ្យយើងងាយស្រួលដើរចូលទៅក្នុងយន្តហោះ អាច អាចរកកន្លែងអង្គុយ អាចរកកន្លែងអង្គុយទៅតាមលេខដែលគាត់បានសរសេរដាក់នៅក្នុងក្រដាសនោះ។

បន្ទាប់មកទៀតរូបភាពទី ៩ ក្រោយពេលដែលគាត់ ក្រោយពេលដែលគាត់ថ្លឹងវ៉ាលិស និងដាក់វ៉ាលិស ក្រោយពេលដែលគាត់ថ្លឹងវ៉ាលិស និងបុគ្គលិកនៅទីនោះ គាត់បានកិបក្រដាសជាប់នៅនឹងវ៉ាលិស និងបញ្ជូនវ៉ាលិសរបស់គាត់ដាក់នៅក្នុងយន្តហោះរួចរាល់ ដាក់នៅក្នុងយន្តហោះរួចរាល់ហើយ និងគាត់បាន និងគាត់បាន និងគាត់បានក្រដាស ដើម្បីដើរចូលទៅក្នុងយន្តហោះ អញ្ចឹងគាត់ក៏បានមក ដើរមកកន្លែងមួយទៀត ដែលកន្លែងមួយទៀតនៅក្នុងរូបភាពទី ៩ នេះ គឺជាកន្លែងដើម្បីធ្វើការឆែកមើលអ៊ិច-រ៉េម្ដងទៀត ប៉ុន្តែនៅទីនេះគឺខុសពីកន្លែងទី ១ ដោយសារនៅទីនេះគាត់អត់ឆែកមើលវ៉ាលិសរបស់គាត់ទេ ដោយសារតែវ៉ាលិសរបស់គាត់ធ្វើអ៊ិច-រ៉េរួចរាល់ហើយ និងគាត់[បាន] និងគាត់បានឲ្យបុគ្គលិកនៅទីនោះដាក់នៅ និងឲ្យបុគ្គលិកនៅទីនោះ គាត់ដាក់នៅក្នុងយន្តហោះ គាត់ដាក់ចូលទៅក្នុងយន្តហោះ ដូច្នេះនៅ នៅទីនេះ គាត់គ្រាន់តែ គាត់គ្រាន់របស់ គាត់គ្រាន់តែដាក់របស់ដែលមានជាប់នៅនឹងខ្លួន ដែលមានដូចជា ខ្សែក្រវាត់ មានទូរស័ព្ទ មានកុំព្យូទ័រ ឬក៏របស់ផ្សេងៗទៀត របស់ របស់ផ្សេងៗទៀត ដើម្បីធ្វើការស្កេន ដើម្បីធ្វើការ ដើម្បីធ្វើការស្កេនអ៊ិច-រ៉េ ដើម្បីឲ្យប្រាកដថាមិនមានរបស់ហាមឃាត់នៅខាងក្នុងនោះ មិនមានរបស់ហាមឃាត់នៅខាងក្នុងនោះ ជាពិសេសប្រសិនបើមានកាំបិត មានកាំបិត អញ្ចឹងគេអត់អនុញ្ញាតឲ្យ អនុញ្ញាតឲ្យយកចូល អនុញ្ញាតឲ្យយកចូលទៅក្នុងយន្តហោះទេ ពីព្រោះគេខ្លាចមានរឿង មានរឿង និងមានបញ្ហាកើតឡើង។ អញ្ចឹងយើងឃើញបុរស យើងឃើញបុរសម្នាក់នោះ ក្រោយពេលដែលគាត់ដើរមកដល់កន្លែងត្រួតពិនិត្យអ៊ិច-រ៉េនោះ គាត់បានដោះខ្សែក្រវាត់របស់គាត់ចេញពីខោ និងគាត់បានដាក់ទូរស័ព្ទ គាត់បានដាក់ គាត់បានដាក់ទូរស័ព្ទ និងបានដាក់កុំព្យូទ័ររបស់គាត់ដាក់ចូលទៅក្នុងថាសមួយ ថាសមួយ និងដាក់នៅលើម៉ាស៊ីន និងម៉ាស៊ីននោះនឹងរុញបញ្ចូលទៅខាងក្នុង ដើម្បីធ្វើការពិនិត្យ ដើម្បីធ្វើការពិនិត្យ។ អញ្ចឹងបុគ្គលិកនៅផ្នែកនេះ គឺគាត់គឺជាមនុស្សស្រី អញ្ចឹងគាត់មាន គឺជាមនុស្សស្រី គាត់មានសក់ត្រឹមក អញ្ចឹងគាត់ពាក់ឯកសណ្ឋានជាអ្នកត្រួតពិនិត្យ និងជាឯកសណ្ឋានជាបុគ្គលិកនៅក្នុងព្រលានយន្តហោះនោះ។ អញ្ចឹងយើងឃើញគាត់អង្គុយ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

នៅខាងមុខគាត់មានកុំព្យូទ័រមួយ មានកុំព្យូទ័រមួយ អញ្ចឹងគាត់ធ្វើការពិនិត្យ
អញ្ចឹងគាត់ធ្វើការពិនិត្យដោយយកចិត្តទុកដាក់ ប្រសិនបើគាត់ធ្វើការពិនិត្យខុស
គាត់អាចមានបញ្ហា។ និងពេលខ្លះនៅក្នុងប្រទេសរបស់គាត់ក៏អាចមានបញ្ហាផងដែរ
អញ្ចឹងក៏អាចមានបញ្ហាផងដែរ។ ដូច្នេះគាត់ត្រូវពិនិត្យមើលដោយយកចិត្តទុកដាក់
អញ្ចឹងគាត់ត្រូវពិនិត្យមើលដោយយកចិត្តទុកដាក់ អញ្ចឹងរបស់ និងពេលខ្លះសូម្បីតែកងដៃ
ឬរបស់ដែលមានជាតិដែក អញ្ចឹងយើងត្រូវដោះដាក់ យើងត្រូវដោះដាក់នៅក្នុងថាសនោះ
ដើម្បីដាក់ចូលទៅក្នុងម៉ាស៊ីន។ ប្រសិនបើយើងអត់ដោះទេ
នៅពេលដែលយើងដើរឆ្លងកាត់ខ្លោងទ្វារមួយទៀត ទ្វារមួយទៀត [...]
ដើរឆ្លងកាត់ខ្លោងទ្វារមួយទៀត ដែលខ្លោងទ្វារនោះក៏ ក៏ជាខ្លោងទ្វារអ៊ិច-រ៉េដែរ ដើម្បីពិនិត្យ
ដើម្បីធ្វើការពិនិត្យ ថាតើមានរបស់ហាមឃាត់នៅខាងក្នុងខ្លួនរបស់យើងអត់។
អញ្ចឹងអ្នកខ្លះគាត់ភ្លេចដោះខ្សែក្រវាត់ អញ្ចឹងនៅពេលដែលគាត់ដើរកាត់ឆ្លង
ដើរកាត់ខ្លោងទ្វារនោះនឹងមានឮសំឡេង។ អញ្ចឹងសន្តិសុខដែលគាត់ធ្វើការនៅទីនោះ
ឬក៏បុគ្គលិកដែលគាត់ធ្វើការនៅទីនោះ គាត់នឹងធ្វើការពិនិត្យម្ដងទៀត គាត់នឹងធ្វើការពិនិត្យម្ដងទៀត
ដើម្បីឲ្យច្បាស់ថាមិនមានរបស់ហាមឃាត់នៅខាងក្នុងខ្លួនរបស់គាត់។

បន្ទាប់មកទៀតរូបភាពទី ១០ រូបភាពទី ១០ ក្រោយពេលគាត់ធ្វើការ ធ្វើការ ធ្វើអ៊ិច-រ៉េ
ពិនិត្យម្ដងទៀតរួចរាល់ហើយ រួចរាល់ហើយ គាត់ក៏បានដើរមកកន្លែងពិនិត្យមើលលិខិតឆ្លងដែន។
ដែលយើងឃើញបុគ្គលិក បុគ្គលិកធ្វើការនៅទីនោះគឺជាមនុស្សប្រុស។ អញ្ចឹងគាត់ពាក់ឯកសណ្ឋាន
មានក្រវាត់ក និងឯកសណ្ឋានជាអ្នកធ្វើការនៅព្រលានយន្តហោះ។
អញ្ចឹងយើងឃើញជាទូទៅគាត់ត្រូវឆែកមើលលិខិតឆ្លងដែនរបស់ភ្ញៀវ ពីព្រោះភ្ញៀវខ្លះគឺគាត់
ពីព្រោះភ្ញៀវខ្លះគឺគាត់ ធ្វើ ធ្វើលិខិតឆ្លងដែនក្លែងក្លាយ ឬក៏ភ្ញៀវខ្លះ ភ្ញៀវខ្លះគឺគាត់ផុតកំណត់ក្នុងការ
ផុតកំណត់ក្នុងការរស់នៅ នៅក្នុងប្រទេសរបស់គាត់ ដូច្នេះគាត់ខុសច្បាប់ អញ្ចឹងអាចខុសច្បាប់។
អញ្ចឹងភ្ញៀវជាធម្មតាគាត់ត្រូវពិនិត្យមើលឆ្លងដែន និងពិនិត្យមើលវីសា និងពិនិត្យមើលវីសា
ដើម្បីឲ្យដឹងថាតើ ដើម្បី ដើម្បីឲ្យដឹងថាតើគាត់នៅប្រទេសរបស់គាត់ប៉ុន្មានថ្ងៃ ឬ
ឬគាត់មកខុសច្បាប់ ឬគាត់គឺជាមនុស្ស ឬគាត់ជាមនុស្សដែលប៉ូលិសតាមចាប់។
អញ្ចឹងកន្លែងដែលពិនិត្យលិខិតឆ្លងដែនក៏ត្រូវធ្វើការយ៉ាងហ្មត់ចត់ និងយកចិត្តទុកដាក់
និងជាពិសេសគាត់ត្រូវពិនិត្យមើលលិខិតឆ្លងដែន និងវីសាឲ្យបានច្បាស់
ឲ្យប្រាកដថាគាត់មិនមែននៅទីនេះខុសច្បាប់។ ដោយសារតែអ្នកខ្លះគឺគាត់នៅរយៈពេលយូរ
និងវីសាផុតកំណត់ និងវីសាផុតកំណត់ ដូច្នេះគាត់អាចរស់នៅប្រទេសរបស់គាត់ដោយខុសច្បាប់។
ដូច្នេះគាត់អាចមានបញ្ហាបាន។ អញ្ចឹងនៅទីនេះគឺជាការពិនិត្យលិខិតឆ្លងដែន
មុនពេលដែលអនុញ្ញាតឲ្យពួកគាត់ធ្វើដំណើរ ឬក៏អនុញ្ញាតឲ្យពួកគាត់ឡើងទៅលើយន្តហោះ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ឡើងទៅលើយន្តហោះ។ និងសព្វថ្ងៃនេះនៅកន្លែងពិនិត្យឆ្លង] ពិនិត្យលិខិតឆ្លងដែន
ភាគច្រើនគឺគាត់ប្រើ ប្រើ អញ្ចឹងគាត់ប្រើម៉ាស៊ីនស្កេនមេដៃ។ មានន័យថាគាត់ឲ្យភ្ញៀវស្កេនមេដៃ
ឬក៏ស្កេនម្រាមដៃ ឬក៏កន្លែងខ្លះទៀត និងកន្លែងខ្លះទៀតគាត់ដាក់កាមេរ៉ា គាត់ថតរូប។
អញ្ចឹងឥឡូវនេះយើងមាន សព្វថ្ងៃនេះនៅព្រលានយន្តហោះ កន្លែងដែលឆែក
កន្លែងដែលឆែកលិខិតឆ្លងដែន គាត់មាន គាត់មានម៉ាស៊ីនសម្រាប់ សម្រាប់ស្កេនមេដៃ
សម្រាប់ស្កេនមេដៃ ឬក៏ម្រាមដៃ និងគាត់មានកាមេរ៉ាសម្រាប់ថត។ អញ្ចឹងមានកាមេរ៉ាសម្រាប់ថត
ប៉ុន្តែជាទូទៅគាត់ថត និងស្កេនមេដៃសម្រាប់តែ សម្រាប់តែភ្ញៀវ
ដែលគាត់ចូលទៅក្នុងប្រទេសរបស់គាត់។ ប៉ុន្តែសម្រាប់ភ្ញៀវដែលចេញទៅ ចេញពីប្រទេសរបស់គាត់
គឺគាត់ គឺគាត់អត់ធ្វើការស្កេន ឬក៏អត់ធ្វើការថតរូបទេ។ អញ្ចឹងគឺគាត់ហ្មត់ចត់នៅពេលដែលភ្ញៀវ
គាត់ចូលមកក្នុងប្រទេសរបស់គាត់ ដើម្បីឲ្យច្បាស់ថាវីសា និងលិខិតឆ្លងដែនរបស់គាត់
មិនមានផុតកំណត់ និងគាត់មិន និងគាត់មិន និងគាត់មិនមករស់នៅទីនេះដោយខុសច្បាប់
និងគាត់មកមិន និងគាត់មិនមករស់នៅទីនេះដោយខុសច្បាប់ អញ្ចឹងលិខិតឆ្លង កន្លែងលិខិតឆ្លងដែន
គាត់ធ្វើការត្រួតពិនិត្យដោយយកចិត្តទុកដាក់។ អញ្ចឹងយើងឃើញបុរសម្នាក់នោះ
យើងឃើញគាត់បានហុចលិខិតឆ្លងដែនរបស់គាត់ឲ្យទៅបុគ្គលិក ដើម្បីធ្វើការត្រួតពិនិត្យ។

រូបភាពទី ១១ ក្រោយពេលដែលគាត់ត្រួតពិនិត្យឯកសាររួចរាល់ហើយ។ អញ្ចឹងគាត់មិន
គាត់នៅសល់ពេល គាត់នៅសល់ពេល ដូច្នេះគាត់ក៏បានដើរមើលនៅក្នុង
គាត់ក៏បានដើរមើលហាងនៅក្នុងព្រលានយន្តហោះនោះ។ ពីព្រោះនៅក្នុងព្រលានយន្តហោះ
ធម្មតាគឺមានហាងលក់របស់ជាច្រើន មានលក់ជាស្រា មានលក់ជា មានលក់ជាវ៉ាញ់ មានលក់ជា
មានលក់ជាស្រាក្រហម មានលក់ជាកាបូប មានលក់ជាសៀវភៅ
មានលក់ជាគ្រឿងអលង្ការណ៍ផ្សេងៗ។ អញ្ចឹងនៅក្នុង
នៅក្នុងព្រលានយន្តហោះមានហាងលក់ជាច្រើន មានហាងលក់ជាច្រើន និងហាងនៅទៅនោះ
ក៏មាន ក៏មានការ ក៏មានការបញ្ចុះតម្លៃ ក៏មានការបញ្ចុះតម្លៃទៅលើមុខទំនិញផ្សេងៗផងដែរ។
មិនត្រឹមតែមានការបញ្ចុះតម្លៃទេ ទំនិញ និងទំនិញខ្លះគឺអត់គិតពន្ធផងដែរ។ អញ្ចឹងបញ្ចុះតម្លៃផង
និងទំនិញខ្លះគឺអត់គិតពន្ធផង។ អញ្ចឹងយើងឃើញគាត់នៅសល់ពេល អញ្ចឹងគាត់បានដើរ
គាត់បានដើរមើលហាងដែលមាននៅក្នុងព្រលានយន្តហោះនោះ។

បន្ទាប់មកទៀតរូបភាពទី ១២ រូបភាពទី ១២ បន្ទាប់មកទៀតក្រោយពេលដែលគាត់ដើរផ្សារ
ដើរផ្សារ ដើរផ្សារហើយ គាត់ក៏បានដើរមកមើលតារាងនៅក្នុងរូបភាពទី ១២ រូបភាពទី ១២
គាត់ក៏បានដើរមកមើលតារាងដើម្បីបង្ហាញថា ដើម្បីបង្ហាញអំពីទីក្រុង ឬក៏ម៉ោងធ្វើដំណើរ ទីក្រុង
ឈ្មោះទីក្រុង ឬក៏ម៉ោងធ្វើដំណើរ។ ដែលយើងឃើញទីក្រុងទី ១ ឈ្មោះស៊ូរិច

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដែលជាទីក្រុងរបស់ប្រទេសស្វីស និងទីក្រុងទី ២ គឺទីក្រុងប៊ែរលីន
គឺជាទីក្រុងរបស់ប្រទេសអាល្លឺម៉ង់។ ជាទូទៅប្រទេសស្វីសមានមនុស្ស ភាគច្រើនគាត់និយាយ
និងគាត់ហៅថាប្រទេសស្វីសគឺជាប្រទេសអ្នកមាន គឺជាប្រទេសអ្នកមាន
អញ្ចឹងប្រជាជននៅប្រទេសស្វីសភាគច្រើនគាត់ គាត់មានការងារ និងភាគច្រើនគឺគាត់គឺជាអ្នក
និងភាគច្រើនគឺគាត់គឺជាអ្នកមានច្រើន គឺជាអ្នកមានច្រើន។ និងទីក្រុងទី ៣ គឺប្រទេស[...]
គឺប្រទេសប៉េកាំង ដែលប្រទេសប៉េកាំង គឺស្ថិតនៅក្នុងប្រទេសចិន ប្រទេសចិន។ អញ្ចឹងប្រទេស
អញ្ចឹងទីក្រុងស៊្វីច ដែលជា ទីក្រុងស៊្វីចនៅក្នុងប្រទេស នៅក្នុងប្រទេសស្វីស
គឺម៉ោងធ្វើដំណើរគឺនៅម៉ោងមួយសែសិបប្រាំនាទី។ ប្រទេសប៊ែរលីននៅក្នុង ទីក្រុង
ក្រុងប៊ែរលីននៅក្នុង នៅក្នុងប្រទេសអាល្លឺម៉ង់គឺធ្វើដំណើរនៅម៉ោងមួយហាសិបនាទី និង
និងទីក្រុងប៉េកាំងនៅក្នុងប្រទេសចិនគឺធ្វើដំណើរនៅម៉ោងមួយហាសិបប្រាំនាទី។ អញ្ចឹងគាត់មើល
គាត់មើលតារាងនោះ ដើម្បីឲ្យដឹងថាម៉ោងណាគាត់ត្រូវឡើងយន្តហោះ ដើម្បីកុំឲ្យខក។
អញ្ចឹងយើងដឹងហើយប្រទេសចិនក៏ជាប្រទេសមហាអំណាចមួយទៅលើ[សេដ្ឋ]
មហាអំណាចមួយដែលមានសេដ្ឋកិច្ចល្អ។ អញ្ចឹងភាគច្រើនទំនិញជាច្រើន
នៅក្នុងប្រទេសកម្ពុជាយើង គឺបាននាំចូលមកពីប្រទេសចិន ដែលមានដូចជាខោអាវ
និងមានរបស់របរប្រើប្រាស់ សម្ភារៈផ្សេងៗទៀតជាច្រើន និងទូរស័ព្ទផងដែរ។
អញ្ចឹងប្រទេសចិនគឺគាត់ គឺគាត់ជាប្រទេសមហាអំណាច ដែលគាត់ខ្លាំងទៅលើទីផ្សារ
ទីផ្សាររបស់គាត់ឥឡូវនេះគឺ ទីផ្សាររបស់គាត់ឥឡូវនេះគឺខ្លាំង។ អញ្ចឹងគាត់បាន
អញ្ចឹងជាក់ស្តែងនៅក្នុងកម្ពុជាយើង គឺមានទំនិញជាច្រើនមកពីប្រទេសចិន។

បន្ទាប់មកទៀតរូបភាពទី ១៣ រូបភាពទី ១៣ ក្រោយពេលដែលគាត់មើលតារាងម៉ោង
និងមើលតារាងទីក្រុង និងម៉ោងដែលត្រូវធ្វើដំណើរ ដែលត្រូវចេញដំណើរ អញ្ចឹងគាត់
អញ្ចឹងហោះហើររបស់គាត់ អញ្ចឹងហោះហើររបស់គាត់ត្រូវចេញដំណើរ។
ដូច្នេះគាត់ក៏បានឡើងមកលើយន្តហោះ អញ្ចឹងគាត់ដើរចូល គាត់ដើរចូលមកក្នុងយន្តហោះ។
អញ្ចឹងមុនពេលដែលគាត់ដើរចូលនៅក្នុងយន្តហោះ គាត់ត្រូវបង្ហាញសំបុត្រយន្តហោះ
និងជាមួយនឹងក្រដាស ដែលយើងហៅថា ឬក៏ក្រដាសដែលយើងហៅថា boarding pass
ដើម្បីឲ្យទៅបុគ្គលិកដែលគាត់ធ្វើការត្រួតពិនិត្យនៅទីនោះ។ អញ្ចឹងក្រដាស boarding pass នោះ
គឺមានបញ្ជាក់អំពី គឺមានសរសេរអំពីច្រកចូល ឬមានសរសេរអំពីច្រកចូល ឈ្មោះ
ឈ្មោះយន្តហោះដែលត្រូវធ្វើដំណើរ និងមានលេខកៅអីផងដែរ។ អញ្ចឹងគាត់បានហុចទៅឲ្យអ្នក
អញ្ចឹងគាត់បានហុចទៅឲ្យអ្នកត្រួតពិនិត្យមើលរួចរាល់ហើយ គាត់ក៏បានដើរចូលមកក្នុងយន្តហោះ។
អញ្ចឹងយើងឃើញកៅអីរបស់គាត់គឺនៅជាប់នឹងបង្អួច
ដែលគាត់អាចមើលទេសភាពនៅខាងក្រៅបាន។ ប៉ុន្តែមុនពេលដែលយន្តហោះធ្វើការហោះហើរ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងភ្ញៀវទាំងអស់នៅក្នុងនោះគាត់ត្រូវពាក់ខ្សែក្រវាត់ការពារ គាត់ត្រូវការពាក់ខ្សែក្រវាត់ការពារ
នៅពេលយន្តហោះ នៅពេលយន្តហោះប្រុងប្រៀបហោះហើរ ប្រុងប្រៀបហោះហើរ។
អញ្ចឹងយើងឃើញបុរសម្នាក់នោះគឺគាត់អង្គុយនៅកៅអីក្បែរនឹងបង្អួច។
និងគាត់បានយកខ្សែក្រវាត់ពាក់ គាត់ពាក់ខ្សែក្រវាត់ ដើម្បី ដើម្បីប្រុងប្រៀបធ្វើការហោះហើរទៅ
ដើម្បីប្រុងប្រៀបធ្វើការហោះហើរត្រលប់ទៅប្រទេសរបស់គាត់វិញ។

អញ្ចឹងយើងឃើញរូបភាពទី ១៤ រូបភាពទី ១៤ យន្តហោះក៏បាន [...]
យន្តហោះក៏ដល់ម៉ោងចេញដំណើរ។ អញ្ចឹងយើងឃើញយន្តហោះបានហោះឡើងទៅខាងលើ
ហោះឡើងទៅខាងលើ និងយើងឃើញថ្ងៃនេះមានអាកាសធាតុល្អដែរ
និងយើងឃើញអាកាសធាតុល្អ អត់មានភ្លៀង។ យើងឃើញមានពន្លឺព្រះអាទិត្យ
និងមានដុំពពកពណ៌សជាច្រើនជាមួយនឹងធម្មជាតិពណ៌បៃតងនៅខាងក្រោម។
អញ្ចឹងនៅពេលដែលយន្តហោះឡើងទៅខាងលើ អញ្ចឹងយើងមើលខាងក្រោមឃើញមានពណ៌បៃតង
និងឃើញមានផ្ទះ មានផ្លូវតូចៗ។ និងនៅពេលដែលយន្តហោះឡើងទៅខាងលើខ្ពស់
អញ្ចឹងពេលខ្លះយើងអត់អាចមើលនៅខាងក្រោមឃើញផ្ទះ និងអត់ឃើញទន្លេ
និងអត់ឃើញផ្លូវនៅខាងក្រោមទេ។ ប៉ុន្តែទេសភាព[មាន]មើលមកខាងក្រោម
គឺមានទេសភាពស្អាត។ អញ្ចឹងគាត់អង្គុយនៅក្បែរបង្អួច
ដូច្នេះគាត់អាចមើលទេសភាពយ៉ាងស្រស់ស្អាតនៅខាងក្រោម នៅខាង
ទេសភាពយ៉ាងស្រស់ស្អាតនៅខាងក្រោម។ អញ្ចឹងយើងឃើញរូបភាពទី ១៤ នេះ យន្តហោះបាន
បានធ្វើការហោះហើរឡើងទៅខាងលើ អញ្ចឹងយន្តហោះបានធ្វើការហោះហើរឡើងទៅខាងលើ។

បន្ទាប់មកទៀតរូបភាពទី ១៥ រូបភាពទី ១៥ នៅពេលដែលយន្តហោះឡើងទៅដល់ខាងលើហើយ
យន្តហោះគឺ គឺនឹងធម្មតា គឺនឹងធម្មតា ដូច្នេះបុគ្គលិកដែលគាត់ធ្វើការនៅក្នុងយន្តហោះ
គាត់បានយកភេសជ្ជៈ និងអាហារផ្សេងៗលើកយកមកឲ្យភ្ញៀវ។ ដែលយើងឃើញនៅពេលដែល
នៅពេលដែល នៅពេលដែលយន្តហោះឡើងទៅដល់ខាងលើហើយ។
យើងអាចបើកនៅកៅអីខាងក្រោយ យើងឃើញមានកៅអីខាង កៅអីនៅខាងមុខ
នៅខាងក្រោយមាន នៅខាងក្រោយមានតុ នៅខាងក្រោយកៅអីខាងមុខគឺមានតុប្រើសម្រាប់ដាក់
ប្រើសម្រាប់ដាក់ម្ហូប ដាក់ទឹក ប្រើសម្រាប់ដាក់ម្ហូប ដាក់ទឹកផ្លែឈើ ឬក៏ទឹកផ្សេងៗដែលគាត់ញ៉ាំ
និងមានទូរទស្សន៍នៅជាប់នឹងកៅអីនោះផងដែរ។ ដូច្នេះភ្ញៀវគាត់អាចញ៉ាំបណ្តើរ គាត់អាចមើល
គាត់អាចមើលទូរទស្សន៍បណ្តើរ។ អញ្ចឹងយើងឃើញនៅលើតុរបស់គាត់ គឺគាត់ញ៉ាំទឹកក្រូច
គាត់ញ៉ាំទឹកក្រូចមួយកំប៉ុង អញ្ចឹងគាត់ចាក់ទឹកក្រូចចូលទៅក្នុងកែវរបស់គាត់

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

និងគាត់មានដោតកាសនៅត្រចៀករបស់គាត់ អញ្ចឹងគាត់កំពុងតែមើលទូរទស្សន៍។
អញ្ចឹងគាត់ញ៉ាំទឹកក្រូចបណ្ដើរ មើលទូរទស្សន៍បណ្ដើរ។

បន្ទាប់មកទៀត បន្ទាប់មកទៀតរូបភាពទី ១៦
ក្រោយពេលដែលធ្វើដំណើរអស់រយៈពេលជាច្រើនម៉ោងហើយ
ជើងយន្តហោះក៏បានធ្វើដំណើរមកដល់ប្រទេសស្វីស] ប្រទេសស្វីស។
ដូច្នេះយន្តហោះក៏បានបន្ទាបខ្លួនម្ដងបន្តិចៗ ដើម្បីចុះមកខាងក្រោម ដើម្បីធ្វើការចុះចតដាក់ភ្ញៀវ
ដាក់ភ្ញៀវនៅខាងក្នុងយន្តហោះនោះ។ អញ្ចឹងយើងឃើញយន្តហោះបន្ទាបម្ដងបន្តិចៗ
ដើម្បីធ្វើការចុះចត។ និងយើងឃើញមានភ្នំ និងយើងឃើញមានភ្នំជាច្រើន
និងមានទឹកកកនៅខាងលើភ្នំនោះ។ អញ្ចឹងនៅប្រទេសស្វីស
នៅប្រទេសស្វីសគឺមានអាកាសធាតុត្រជាក់។ អញ្ចឹងមានន័យថាគឺនៅរដូវ រដូវរងា
អញ្ចឹងរដូវរងាមានធ្លាក់ព្រិលទឹកកក មានធ្លាក់ មានធ្លាក់ព្រិលទឹកកក
ដែលនៅតំបន់ភ្នំយើងឃើញដែល ដែលយើងឃើញនៅលើភ្នំ នៅកំពូលភ្នំ ឬក៏នៅលើភ្នំនីមួយៗ
យើងឃើញមានទឹកកកគ្របដណ្ដប់ អញ្ចឹងយើងឃើញមានទឹកកកគ្របដណ្ដប់ជាមួយនឹងខ្យល់
ជាមួយនឹងខ្យល់។ ដូច្នេះនៅប្រទេសស្វីស  គឺមាន គឺមានអាកាសធាតុត្រជាក់ខ្លាំង
គឺមានអាកាសធាតុត្រជាក់ខ្លាំង។ អញ្ចឹងយន្តហោះបាន បានបន្ទាបខ្លួន ដើម្បីធ្វើការចុះចត
ដើម្បីធ្វើការចុះចត។

បន្ទាប់មកទៀតរូបភាពចុងក្រោយ រូបភាពទី ១៧ ក្រោយពេលដែលយន្តហោះធ្វើការចុះចត។
អញ្ចឹងភ្ញៀវទាំងអស់នៅលើយន្តហោះ បានចុះពីលើយន្តហោះ។ អញ្ចឹងបុរសម្នាក់នោះ
គាត់បានចុះពីលើយន្តហោះ និងដើរមកកន្លែងដែលគាត់ត្រូវយកវ៉ាលិសរបស់គាត់។
អញ្ចឹងវ៉ាលិសរបស់ភ្ញៀវ ដែលបុគ្គលិកនៅក្នុងព្រលានយន្តហោះ
គាត់បានយកដាក់នៅខាងក្រោមយន្តហោះនោះ។ អញ្ចឹងនៅពេលដែលយន្តហោះចុះចត។ ពួកគាត់
បុគ្គលិកនៅទីនោះនឹងយកវ៉ាលិសទាំងអស់នោះ យកមកដាក់នៅលើម៉ាស៊ីនបង្វិល ដើម្បីឲ្យភ្ញៀវគាត់
ដើម្បីឲ្យភ្ញៀវគាត់យកវ៉ាលិសរបស់គាត់ងាយស្រួល។ អញ្ចឹងវ៉ាលិសទាំងអស់
គឺដាក់នៅលើម៉ាស៊ីនបង្វិលនោះ។ អញ្ចឹងភ្ញៀវគ្រាន់តែមកឈរចាំមើលវ៉ាលិសរបស់គាត់
និងនៅពេលដែលគាត់ឃើញវ៉ាលិសរបស់គាត់ គាត់អាចយកវ៉ាលិសរបស់គាត់
ចេញពីម៉ាស៊ីនបង្វិលនោះ។ អញ្ចឹងបុរសម្នាក់នោះ គាត់ឈរ
យើងឃើញគាត់ឈរដាក់ដៃក្នុងហោប៉ៅរបស់គាត់ ឈរចាំយកវ៉ាលិសរបស់គាត់
នៅលើម៉ាស៊ីនបង្វិលនោះ។ អញ្ចឹងក្រោយពេលដែល ក្រោយពេលដែលឈប់សម្រាកពីការងារ
លំហែកាយនៅតំបន់ នៅឆ្នេរសមុទ្រ នៅឆ្នេរសមុទ្ររយៈពេលប៉ុន្មានថ្ងៃរួចមក។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងគាត់ក៏បានត្រលប់មកប្រទេសរបស់គាត់វិញ ដែលប្រទេសរបស់គាត់គឺជាប្រទេសស្វីស ដែលមានអាកាសធាតុត្រជាក់ ដែលមានអាកាសធាតុត្រជាក់ មានព្រិលទឹកកក។ អញ្ចឹងគាត់ក៏បានត្រលប់មកប្រទេសរបស់គាត់វិញ និងធ្វើការដូចធម្មតា។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.